ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខ: ១៤៣/២៣ អអរ

## សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តកែប"

នាព្រឹកថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តកែប»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តមបណ្ឌិត សោម ពិសិដ្ឋ អភិបាល នៃគណៈអភិបាលខេត្តកែប**
- **មន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្តកែប**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យដែលរដ្ឋបាលខេត្តកែប ខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

## I. ស្ថានភាពទូទៅ

ខេត្តកែប បែងចែកចេញជាក្រុង១ ស្រុក១ ឃុំ២ សង្កាត់៣ និង១៨ភូមិ ដែលមានប្រជាពលរដ្ឋរស់នៅសរុបចំនួន ៤៤.៥២៣នាក់ ស្មើនឹង ២២.៨២២គ្រួសារ។ សេដ្ឋកិច្ចខេត្តមានទំហំប្រមាណ ៥៤លានដុល្លារអាមេរិក ស្មើនឹង ០,២% នៃសេដ្ឋកិច្ចជាតិ ចំណូលសម្រាប់មនុស្សម្នាក់ មានចំនួន ១.២០៦ដុល្លារអាមេរិក។

## II. សមិទ្ធផលការងារ

ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ(២០១៨-២០២២) សមិទ្ធផលការងារសំខាន់ៗ ដែលសម្រេចបានរួមមាន៖

- **វិស័យគាំពារសង្គម៖** រដ្ឋបាលខេត្ត បានអនុវត្តនូវគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល ដោយបានឧបត្ថម្ភជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ចំនួន ២.២៨៩គ្រួសារ ចំណាយថវិកា ១២.៨៧៦.៣៦៤.០០០រៀល, ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ចំណាយថវិកា ១៦៩.៤០០.០០០រៀល, គ្រួសារងាយរងហានិភ័យដោយសម្ពាធអតិផរណា សរុប ៦៣៦គ្រួសារ ចំណាយថវិកា ៨៤.៦១៥.៨០០រៀល។
- **ការងារទេសចរណ៍ ធនធានធម្មជាតិ និងបរិស្ថាន៖** ជាខេត្តដែលមានធនធានធម្មជាតិអំណោយផលដល់វិស័យទេសចរណ៍ ក្នុងនោះ មានឆ្នេរសមុទ្រវែង កោះ ថ្មប៉ប្រះទឹក ព្រៃកោងកាង តំបន់ផ្កាថ្មនិងស្មៅសមុទ្រ មានសត្វសមុទ្រដ៏កម្រដូចជា ជ្រូកសមុទ្រ អណ្តើកសមុទ្រ ត្រីសេះ ត្រីផ្សោតជាដើម ព្រមទាំងរៀបចំឱ្យមានធនាគារក្តាម ក្នុងន័យកាត់បន្ថយការធ្វើនេសាទដោយធម្មជាតិ។ ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ ខេត្តទទួលបានភ្ញៀវទេសចរសរុប ៦.៧០៤.០៣៥នាក់ ក្នុងនោះភ្ញៀវជាតិ ៦.៥៥១.២៣១នាក់។ រដ្ឋបាលខេត្ត បានខិតខំអភិវឌ្ឍន៍ ដើរទន្ទឹមគ្នាជាមួយនឹងការអភិរក្ស ទៅលើធនធានធម្មជាតិដែលមានស្រាប់ សំដៅកែប្រែភូមិសាស្ត្រខេត្ត ឱ្យទៅជាទីក្រុងទេសចរណ៍ធម្មជាតិ បរិស្ថានបៃតង ជាគោលដៅដ៏សំខាន់ ក្នុងការទាក់ទាញភ្ញៀវទេសចរបន្ថែមទៀត។
- **វិស័យកសិកម្ម និងឧស្សាហកម្ម៖** ខេត្តមានផ្ទៃដីដំណាំស្រូវចំនួន ៣.៦០៣ហិកតា ទទួលបានទិន្នផលជាមធ្យម ៣.៣៨៥តោន ក្នុងមួយហិកតា, ដំណាំអចិន្ត្រៃយ៍ (ទុរេន ស្វាយ ម្រេច) ចំនួន ១.៣៦៨ហិកតា បរិមាណផល ៨៤.៩៤៥តោន, ស្រែអំបិលចំនួន ៩៩៥,១២ហិកតា ផលិតអំបិលបាន ១០.០៣៣តោន។ ជាមួយគ្នានេះ រដ្ឋបាលខេត្តបានចងក្រងក្រុមកសិករផលិត និងបានអប់រំបណ្តុះបណ្តាលចំណេះដឹងទាក់ទងនឹងអាជីវកម្ម និងទីផ្សារបានចំនួន ១៣១វគ្គ។
- **ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ៖** តាមរយៈការដាក់ចេញនូវគោលការណ៍ច្បាប់សមស្រប ការរៀបចំឱ្យមានកងកម្លាំងចល័តប្រចាំការគ្រប់ពេលវេលា ទូទាំងខេត្តធានាបាននូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈបានយ៉ាងល្អប្រសើរ ជាពិសេសធានាបាននូវសុខសុវត្ថិភាពទាំងផ្លូវចិត្ត និងផ្លូវកាយជូនប្រជាពលរដ្ឋ គណៈប្រតិភូជាតិ និងអន្តរជាតិ ព្រមទាំងភ្ញៀវទេសចរក្នុងការចូលមកបំពេញបេសកកម្ម និងមកទស្សនាខេត្ត។ ជាមួយគ្នានេះ តាមរយៈការអនុវត្តយ៉ាងខ្ជាប់ខ្ជួន នូវគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ធ្វើឱ្យបទល្មើសគ្រប់ប្រភេទត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ និងទទួលបានចំណាត់ថ្នាក់ល្អ ក្នុងចលនាប្រលងប្រណាំងភូមិ-ឃុំសុវត្ថិភាព

ផងដែរ។ ខេត្តក៏បានរក្សានូវកិច្ចសហប្រតិបត្តិការយ៉ាងល្អ ជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ទាំងការងារសន្តិសុខលើតំបន់ទឹកប្រវត្តិសាស្ត្រ និងការទប់ស្កាត់បទល្មើសឆ្លងដែន។

- **ការផ្តល់សេវាសាធារណៈ៖** រដ្ឋបាលខេត្តបានដាក់ឱ្យអនុវត្តនូវយន្តការច្រកចេញ-ចូលតែមួយនៅថ្នាក់ឃុំ-សង្កាត់ទូទាំងខេត្តអស់ ដោយបានផ្តល់សេវាជូនប្រជាពលរដ្ឋសរុប ៧៧.៣៥៤សេវា។
- **ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ៖** រដ្ឋបាលខេត្ត បានខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ប្រព័ន្ធលូរំដោះទឹក ការរៀបចំឱ្យមានផ្លូវថ្មើជើងជាដើម ក្នុងន័យសម្រួលដល់ការដឹកជញ្ជូនទំនិញ និងការធ្វើដំណើររបស់ប្រជាពលរដ្ឋកាន់តែងាយស្រួល។ ខេត្តកែប ធ្លាប់តែជាខេត្តដែលប្រើប្រាស់ទឹកក្រោមដី ប៉ុន្តែបច្ចុប្បន្ននេះ រដ្ឋបាលខេត្តបានខិតខំរៀបចំឱ្យមានទឹកស្អាតជូនប្រជាពលរដ្ឋប្រើប្រាស់បានចំនួន ៤០%រួចមកហើយ។

## III. ទិសដៅការងារបន្ត

- បន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួនរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តដែលមាននៅជាធរមាន
- ថែរក្សាសន្តិភាព អនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព
- បន្តអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ផែនការអភិវឌ្ឍន៍ជាតិ យុទ្ធសាស្ត្រចតុកោណ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ជាពិសេសច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឱ្យបានខ្ជាប់ខ្ជួន និងប្រកបដោយប្រសិទ្ធភាព
- រៀបចំផែនការការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៃរដ្ឋសភា ឱ្យទទួលបានលទ្ធផលល្អប្រសើរ
- បន្តប្រយុទ្ធប្រឆាំងជំងឺឆ្លង និងជំងឺមិនឆ្លង តាមរយៈចុះផ្សព្វផ្សាយ អប់រំណែនាំប្រជាពលរដ្ឋនៅមូលដ្ឋាន តាមសារអប់រំណែនាំរបស់ក្រសួងសុខាភិបាលជាប្រចាំ
- បន្តចុះក្តាប់បញ្ហាទុក្ខកង្វល់ សំណើ សំណូមពរ រកដំណោះស្រាយ ដើម្បីឆ្លើយតបតម្រូវការជាក់ស្តែងជូនប្រជាពលរដ្ឋនៅមូលដ្ឋានឱ្យបានសកម្មថែមទៀត
- ត្រៀមអនុវត្តផែនការមេសម្រាប់អភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តកែប ២០២១-២០៣៥ ឱ្យទទួលបានលទ្ធផលប្រសើរ។ d

ថ្ងៃព្រហស្បតិ៍ ៧រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣